# សេវាកម្មផ្នែកការយកកូនចេញ និងការរៀបចំផែនការគ្រួសារ
## នៅក្នុងខោនធី LOS ANGELES

ការទទួលបានសេវាកម្មផ្នែករៀបចំផែនការគ្រួសារ និងសុខភាពបន្តពូជដែលមានគុណភាពខ្ពស់ ទាន់ពេលវេលា និងក្នុងលក្ខណៈពេញលេញ គឺជាចំណុចចាំបាច់ចំពោះសុខភាពរបស់បុគ្គលម្នាក់ៗ ក្រុមគ្រួសារ និងសហគមន៍ ផងដែរ។




សេចក្តីណែនាំនេះពិពណ៌នាអំពីធនធានផ្សេងៗដែលអាចរកបាននៅក្នុងខោនធី Los Angeles សម្រាប់បុគ្គលទាំងឡាយណាដែលត្រូវការសេវាកម្មថែទាំទាក់ទងទៅនឹងការយកកូនចេញ សេវាកម្មផ្នែកពន្យារកំណើត ឬសេវាកម្មពាក់ព័ន្ធផ្សេងៗ។

ព័ត៌មាននៅក្នុងសេចក្តីណែនាំនេះនឹងធ្វើឱ្យទាន់ហេតុការណ៍ជាប្រចាំ ដើម្បីបង្ហាញពីចំណុចដែលមានការប្រែប្រួលផ្សេងៗផ្នែកថែទាំសុខភាពបន្តពូជនៅក្នុងខោនធី។ ធនធានផ្សេងៗនៅក្នុងផ្នែកនីមួយៗគឺរៀបរាប់តាមលំដាប់នៃតួអក្សរភាសាអង់គ្លេស។

## តើនរណាខ្លះជាអ្នកផ្តល់សេវាកម្មផ្នែកការយកកូនចេញ នៅក្នុងខោនធី LA?

ការថែទាំផ្នែកការយកកូនចេញគឺអាចរកបាន និងអាចទទួលសេវាកម្មនេះបាននៅក្នុងខោនធី LA។ ការយកកូនចេញគឺមានចេញថ្លៃចំណាយជូនដោយធានារ៉ាប់រងសុខភាពនៅក្នុងរដ្ឋ California រួមទាំងកម្មវិធីធានារ៉ាប់រង Medi-Cal ផងដែរ។ សូមកត់សម្គាល់ថាបុគ្គលទាំងអស់នៅក្នុងរដ្ឋ California ដែលមានប្រាក់ចំណូលទាបអាចទទួលជំនួយពីកម្មវិធីធានារ៉ាប់រង Medi-Cal បានក្នុងអំឡុងពេលមានផ្ទៃពោះ ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។ ការយកកូនចេញគឺអាចធ្វើទៅបានដោយការប្រើប្រាស់ថ្នាំពេទ្យ (ថ្នាំគ្រាប់) ឬតាមរយៈដំណើរការនៅក្នុងគ្លីនិក ដោយអាស្រ័យទៅលើការសម្រេចចិត្តរបស់អ្នកជំងឺ ក៏ដូចជាស្ថានភាពសុខភាពនិងស្ថានភាពនៃការរស់នៅរបស់បុគ្គល ហើយនិងដំណាក់កាលនៃការមានផ្ទៃពោះ ផងដែរ។

ក្នុងករណីមួយចំនួន ពេទ្យសម្ភព ឬពេទ្យរោគស្ត្រី (OB-GYN) ឯកជន ឬក៏គិលានុបដ្ឋាយិកាជំនាញឬពេទ្យឆ្មបអាចផ្តល់នូវការថែទាំផ្នែកការយកកូនចេញបាន។ ក្នុងករណីភាគច្រើន សេវាកម្មផ្នែកការយកកូនចេញគឺមានផ្តល់ជូនដោយពេទ្យ OB-GYN ដែលទទួលបានការបង្ហាត់សម្រាប់ការថែទាំដោយជំនាញឯកទេសនេះ។

**អ្នកផ្តល់សេវាកម្មផ្នែកការយកកូនចេញ នៅក្នុងខោនធី Los Angeles រួមមានដូចជា៖**

**Cedars Sinai | Family Planning Program (កម្មវិធីរៀបចំផែនការគ្រួសារ)**
គេហទំព័រ៖
https://www.cedars-sinai.org/programs/gynecology/clinical-programs/family-planning.html
លេខទូរស័ព្ទ៖ 310-423-3946 (បើកបម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 4:30 ល្ងាច)

គ្លីនិកដែលអាចទៅជួបដោយផ្ទាល់បាន ហើយដែលមានផ្តល់ជូនសេវាកម្មផ្នែករៀបចំផែនការគ្រួសារយ៉ាងពេញលេញ ក៏ដូចជាការថែទាំផ្នែកការយកកូនចេញដោយការប្រើប្រាស់ថ្នាំគ្រាប់ និងដោយការវះកាត់ ផងដែរ។

**FPA Women's Health**
គេហទំព័រ៖ https://www.fpawomenshealth.com/abortion (សម្រាប់ផ្នែកការយកកូនចេញ)
ទូរស័ព្ទ ឬផ្ញើសារជាអក្សរទៅកាន់លេខ 877- 883-7264 (បើកបម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច)
គ្លីនិកដែលអាចទៅដោយផ្ទាល់ អាចទាក់ទងតាមអនឡាញ និងពីចម្ងាយបាន ហើយដែលមានផ្តល់ជូនសេវាកម្មផ្នែករោគស្ត្រី ផ្នែកពន្យារកំណើត និងផ្នែកធ្វើតេស្តរកការឆ្លងមេរោគតាមផ្លូវភេទ (STI) ផងដែរ។
គេហទំព័រ៖ https://www.fpawomenshealth.com/telehealth
(សម្រាប់ផ្នែកការថែទាំសុខភាពពីចម្ងាយ)

**Her Care**
គេហទំព័រ៖ https://hercare.org/
លេខទូរស័ព្ទ៖ 213-516-8580 (ចាប់ពីម៉ោង 9 ព្រឹក ដល់ម៉ោង 6 ល្ងាច)
អ្នកផ្តល់សេវាកម្មឯកជនផ្នែកការរៀបចំផែនការគ្រួសារ ផ្នែកវះកាត់កែសម្ផស្ស និងផ្នែកការយកកូនចេញ សម្រាប់ស្ត្រីដែលមានអាយុចាប់ពី 15 ឆ្នាំ ទៅ 65 ឆ្នាំ ហើយមានទីតាំងចំនួនបីកន្លែងនៅក្នុងខោនធី LA។

**LA County Department of Health Services (DHS)**
គេហទំព័រ៖ https://dhs.lacounty.gov/womens-health/our-services/womens-health/abortion/care121/
លេខទូរស័ព្ទ៖ (877)-CARE121 (បើកបម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 7:30 ព្រឹក ដល់ម៉ោង 6:30 ល្ងាច ម៉ោងស្តង់ដារប៉ាស៊ីហ្វិក)
សេវាកម្មការយកកូនចេញដោយឯកជន និងសម្ងាត់ ដោយឥតគិតថ្លៃនិងមានតម្លៃទាបសម្រាប់បុគ្គលគ្រប់រូបនៅគ្រប់អាយុទាំងអស់។ ផ្តល់ជំនួយបន្ថែមដោយផ្តោតលើបុគ្គលម្នាក់ៗ រួមមានការប្រឹក្សា ព័ត៌មានវេជ្ជសាស្ត្រ និងការអប់រំ និងតម្រូវការផ្សេងទៀតដូចជាការដឹកជញ្ជូន ការទទួលបានអាហារមានសុខភាពល្អ ការស្វែងរកការថែទាំកុមារ និងច្រើនទៀត។

**Luna Flow**
គេហទំព័រ៖ https://www.lunaflowhealth.com/
ការយកកូនចេញតាមរយៈការប្រើប្រាស់ថ្នាំពេទ្យជាលក្ខណៈឯកជន ដោយសេវាកម្មថែទាំសុខភាពពីចម្ងាយនៅក្នុងរដ្ឋ California សម្រាប់ការមានផ្ទៃពោះរហូតដល់រយៈពេល 10 សប្តាហ៍។ សេវាកម្មដោយផ្ទាល់ក៏អាចរកបាននៅក្នុងតំបន់ខោនធី Los Angeles ផងដែរ។

**My Choice Medical Center**
គេហទំព័រ៖ https://www.mychoicemedicalcenter.com/
លេខទូរស័ព្ទ៖ 866-397-3070 មានផ្តល់ជូនពេញមួយថ្ងៃដោយការណាត់ជួបតែប៉ុណ្ណោះ
មណ្ឌលថែទាំសុខភាព My Choice (My Choice Medical Center) គឺជាទីកន្លែងផ្តល់ការថែទាំសុខភាពមានគ្រប់សេវាកម្មបែបឯកជនមួយដែលមានផ្តល់ជូនសេវាកម្មផ្នែកយកកូនចេញ ផងដែរ។

**Planned Parenthood Los Angeles (PPLA)**
គេហទំព័រ៖ https://www.plannedparenthood.org/planned-parenthood-los-angeles
លេខទូរស័ព្ទ៖ 800-576-5544 (បើកបម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ចាប់ពីម៉ោង 8 ព្រឹក ដល់ 5 ល្ងាច)
Planned Parenthood Los Angeles ផ្ដល់ការថែទាំផ្នែកសុខភាពបន្តពូជយ៉ាងពេញលេញ ជូនដល់សហគមន៍នានានៅទូទាំងខោនធី LA។

**Planned Parenthood Pasadena and San Gabriel Valley (PPPSGV)**
គេហទំព័រ៖ https://www.plannedparenthood.org/planned-parenthood-pasadena-san-gabriel-valley
លេខទូរស័ព្ទ៖ 626-798-7938
Planned Parenthood Pasadena និង San Gabriel Valley
ផ្ដល់ជូនការថែទាំផ្នែកសុខភាពបន្តពូជយ៉ាងពេញលេញ។ អាចទៅកាន់ទីនោះដោយផ្ទាល់ ឬក៏ធ្វើការណាត់ជួបនៅក្នុងថ្ងៃតែមួយ ឬការណាត់ជួបតាមរយៈវីដេអូបាន ជាមួយនឹងអ្នកផ្ដល់សេវាកម្មផ្នែកថែទាំសុខភាព។

**UCLA | OBGYN Division of Family Planning (ផ្នែករៀបចំផែនការគ្រួសារនៃគ្លីនិករោគស្ត្រី)**
គេហទំព័រ៖ https://www.uclahealth.org/obgyn/family-planning
ទាក់ទងទៅអ្នកសម្របសម្រួល (coordinator) តាមរយៈលេខ៖ 310-825-5961
ម៉ោងបម្រើការ៖ ពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បត្តិ៍ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច ហើយសម្រាប់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 4:30 ល្ងាច។
សម្រាកពេលបាយថ្ងៃត្រង់ចាប់ពីម៉ោង 12 ដល់ម៉ោង 1 រសៀល។
គ្លីនិកនេះផ្ដល់ជូនសេវាកម្មផ្នែកសុខភាពបន្តពូជយ៉ាងពេញលេញ។

## តើខ្ញុំអាចស្វែងរកទីតាំងដែលផ្តល់សេវាកម្មផ្នែកការយកកូនចេញបានដោយការវះកាត់ និងដោយការប្រើប្រាស់ថ្នាំពេទ្យ នៅក្នុងតំបន់ ហើយនិងថ្នាក់ជាតិ នៅកន្លែងណាខ្លះ?

ការយកកូនចេញគឺជាការស្របច្បាប់ និងមានសុវត្ថិភាព នៅក្នុងរដ្ឋ California។ ការថែទាំផ្នែកការយកកូនចេញនៅក្នុងរដ្ឋ California គឺអាចរកបានសម្រាប់អ្នកមានផ្ទៃពោះទាំងអស់ នៅអាយុប៉ុន្មានក៏ដោយ **ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ ឬកន្លែងដែលអ្នករស់នៅឡើយ។**

គេហទំព័រថ្នាក់ជាតិទាំងនេះជួយដល់អ្នកដែលចង់ទទួលបានព័ត៌មានបន្ថែមអំពីទីកន្លែង និងរបៀបដែលអាចយកកូនចេញបាន។

**Abortion Finder**
គេហទំព័រ៖ https://www.abortionfinder.org/
គេហទំព័រដែលមានឈ្មោះមណ្ឌលសុខភាពច្រើនជាង 700 កន្លែង និងបញ្ជីរាយព័ត៌មានទំនាក់ទំនងយ៉ាងពេញលេញរបស់អ្នកផ្តល់សេវាកម្មផ្នែកយកកូនចេញដែលមានការបញ្ជាក់ត្រឹមត្រូវ។

**ACCESS Reproductive Justice**
គេហទំព័រ៖ https://accessrj.org/
(បម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បត្តិ៍ ចាប់ពីម៉ោង 10 ព្រឹក ដល់ម៉ោង 4 ល្ងាច)

បណ្តាញទូរស័ព្ទថែទាំសុខភាពជាភាសាអង់គ្លេស៖ 800-376-4636 (បម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង 10 ព្រឹក ដល់ម៉ោង 4 ល្ងាច)
បណ្តាញទូរស័ព្ទថែទាំសុខភាពជាភាសាអេស្ប៉ាញ៖ 888-442-2237
បណ្តាញទូរស័ព្ទថែទាំសុខភាពសម្រាប់ផ្ញើសារជាអក្សរ៖ 510-925-0335
បណ្តាញទូរស័ព្ទ (ជាភាសាអង់គ្លេស និងភាសាអេស្ប៉ាញ) មានផ្តល់ព័ត៌មានដោយមិនគិតថ្លៃ និងមានរក្សាការសម្ងាត់ ព្រមទាំងការបញ្ជូនឈ្មោះ ការគាំទ្រមតិ ហើយនិងការប្រឹក្សាពីអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នាអំពីបញ្ហាសុខភាពបន្តពូជ និងបញ្ហាសុខភាពផ្លូវភេទជាច្រើនប្រភេទ ដោយមានឯកទេសលើជម្រើសនៃការមានផ្ទៃពោះ និងសេវាកម្មផ្នែកការយកកូនចេញ ផងដែរ។

### Aid Access
គេហទំព័រ៖ https://aidaccess.org/
អង្គការ Aid Access ធ្វើកិច្ចការផ្សេងៗ ដើម្បីកែលម្អស្ថានភាពសុខភាព និងសិទ្ធិរបស់ស្ត្រីទាំងឡាយដែលមិនអាចទទួលបានសេវាកម្មផ្នែកការយកកូនចេញនៅក្នុងតំបន់ទេនោះ។

### American College of Obstetricians and Gynecologists (ACOG)
គេហទំព័រ៖ https://www.acog.org/womens-health/faqs/induced-abortion
មានផ្តល់ព័ត៌មានផ្នែកសុខភាពដែលផ្អែកទៅលើភស្តុតាងអាចទុកចិត្តបាន ដោយផ្តោតទៅលើសុខភាពរបស់ស្ត្រី។

### California Abortion Access
គេហទំព័រ៖ https://www.cdph.ca.gov/programs/ohe/abortion/pages/home.aspx
គេហទំព័ររបស់រដ្ឋ California នេះរៀបរាប់អំពីព័ត៌មានដែលទាន់ហេតុការណ៍ និងត្រឹមត្រូវ អំពីរបៀបដែលអ្នកអាចទទួលបានសេវាកម្មផ្នែកការយកកូនចេញនៅក្នុងរដ្ឋ California។

### Hey Jane
គេហទំព័រ៖ https://www.heyjane.co/
ផ្ញើសារជាអក្សរទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពតាមរយៈលេខ 405-643-7957 គ្លីនិកតាមអនឡាញមួយដែលផ្តល់ជូនថ្នាំគ្រាប់សម្រាប់យកកូនចេញ ហើយដែលដឹកជញ្ជូនទៅដល់ផ្ទះរបស់អ្នក។

### INeedAnA
គេហទំព័រ៖ https://www.ineedana.com/
"I Need an A"
គឺជាវេទិកាពិភាក្សាតាមអនឡាញមួយដែលអាចផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកបានជាភាសាអង់គ្លេស និងភាសាអេស្ប៉ាញ ហើយដែលជួយដល់អ្នកប្រើប្រាស់ទាំងឡាយក្នុងការស្វែងរកធនធាន និងគ្លីនិកផ្សេងៗនៅក្នុងតំបន់របស់ពួកគេ ឬលេខកូដតំបន់រស់នៅ (zip code) ណាមួយដែលពួកគេជ្រើសរើស។

### Miscarriage + Abortion Hotline (បណ្តាញទូរស័ព្ទបន្ទាន់ទាក់ទងទៅនឹងករណីកូនស្លាប់មុនកើត និងការយកកូនចេញ)
គេហទំព័រ៖ https://www.mahotline.org/
លេខទូរស័ព្ទ៖ 833-246-2632 ម៉ោងដំណើរការសម្រាប់បណ្តាញទូរស័ព្ទបន្ទាន់៖ ចាប់ពីម៉ោង 5 ព្រឹក ដល់ម៉ោង 10 យប់ ម៉ោងប៉ាស៊ីហ្វិក

ស្វែងរកជំនួយដែលមានរក្សាការសម្ងាត់ ហើយនិងគ្រប់គ្រងចំពោះករណីកូនស្លាប់មុនកើត ឬការយកកូនចេញដោយខ្លួនឯង។ សូមទូរស័ព្ទ ឬផ្ញើសារជាអក្សរទៅកាន់បុគ្គលិកនៅគ្លីនិកដែលមានបទពិសោធន៍ជាច្រើនឆ្នាំលើផ្នែកថែទាំសម្រាប់ករណីកូនស្លាប់មុនកើត និងការយកកូនចេញ។

**National Abortion Federation**
គេហទំព័រ៖ https://prochoice.org/patients/find-a-provider/
ផែនទីមួយដែលអាចផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកបានតាមអនឡាញ ដើម្បីស្វែងរកអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពមួយដែលនៅជិតអ្នក (សម្រាប់សហរដ្ឋអាមេរិក ប្រទេសម៉ិកស៊ិក និងប្រទេសកាណាដា)។ សម្រាប់ព័ត៌មានបន្ថែមអំពីការយកកូនចេញ និងធនធានផ្សេងទៀត រួមទាំងជំនួយផ្នែកការបង់ប្រាក់ផងដែរនោះ សូមទូរស័ព្ទទៅកាន់លេខ 1-800-772-9100។

**Plan C**
គេហទំព័រ៖ https://www.plancpills.org/
អង្គការ Plan C ផ្តល់ជូននូវព័ត៌មានទាន់ហេតុការណ៍ជាភាសាអង់គ្លេស និងភាសាអេស្ប៉ាញ ដើម្បីជួយដល់អ្នកដែលរស់នៅក្នុងសហរដ្ឋអាមេរិកទទួលបានជម្រើសតាមអនឡាញអំពីវិធីយកកូនចេញដោយប្រើប្រាស់ថ្នាំគ្រាប់ ហើយដោយមិនចាំបាច់ចាកចេញពីផ្ទះ។

**Women’s Health Specialists**
គេហទំព័រ៖ https://www.womenshealthspecialists.org/
លេខទូរស័ព្ទ៖ 800-714-8151 (បម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8:30 ព្រឹក ដល់ម៉ោង 5 ល្ងាច)
ជនធាននេះផ្តល់ជំនួយ ការអប់រំ និងសេវាកម្មផ្សេងៗផ្នែកសុខភាពបន្តពូជ។

# សេវាកម្មផ្នែកការយកកូនចេញ និងការរៀបចំផែនការគ្រួសារ
## នៅក្នុងខោនធី LOS ANGELES

## ការរំលឹក៖ សូមប្រុងប្រយ័ត្នចំពោះការផ្សព្វផ្សាយពាណិជ្ជកម្មមិនពិត

មណ្ឌលដោះស្រាយវិបត្តិនៃការមានផ្ទៃពោះ (Crisis Pregnancy Centers/CPCs) ដែលស្គាល់ផងដែរថាជាមណ្ឌលផ្តល់ធនធានសម្រាប់ពេលមានផ្ទៃពោះ (Pregnancy Resource Centers) នោះ គឺជាទីកន្លែងបើកដំណើរការដោយឯកជនដែលមើលទៅហាក់បីដូចជាគ្លីនិកថែទាំសុខភាព ប៉ុន្តែជាញឹកញាប់គឺមិនមានបុគ្គលិកដែលជាអ្នកផ្តល់សេវាកម្មផ្នែកពេទ្យពិតប្រាកដឡើយ។ នៅក្នុងរដ្ឋ California និងនៅទូទាំងប្រទេស ទីកន្លែងទាំងនេះមានចំនួនទីតាំងច្រើនជាងគ្លីនិកដែលអនុវត្តការយកកូនចេញទៀតផង ហើយជាទូទៅ ទីកន្លែងទាំងនេះមានទីតាំងស្ថិតនៅជិតគ្លីនិកផ្នែកការយកកូនចេញពិតប្រាកដ ផងដែរ។ នៅតាមអនឡាញ បុគ្គលទាំងឡាយអាចងាយស្រួលនឹងគិតថាទីកន្លែងទាំងនេះជាគ្លីនិកសម្រាប់ការយកកូនចេញ លុះត្រាតែពួកគេអានការពិពណ៌នាអំពីទីកន្លែងទាំងនេះឱ្យបានល្អិតល្អន់។

ជាទូទៅ ទីកន្លែង CPCs គឺដំណើរការដោយអង្គការផ្សេងៗដែលពាក់ព័ន្ធទៅនឹងសាសនា និងផ្តល់ជូននូវការធ្វើតេស្តរកមើលការមានផ្ទៃពោះ ការថតឆ្លុះដោយប្រើប្រាស់រលកសំឡេង (ការឆ្លុះអេកូ/ultrasound) ហើយនិងផ្តល់របស់របរប្រើប្រាស់ជូនដល់ឪពុកម្តាយដែលមានផ្ទៃពោះ និងកូនតូចៗ ដោយមិនគិតថ្លៃ ឬក៏ជាការដោះដូរដើម្បីឱ្យអតិថិជនចូលរៀនវគ្គសិក្សានានា។ ទីកន្លែង CPCs មួយចំនួននៅក្នុងរដ្ឋ California ផ្តល់ជូនសេវាកម្មផ្នែកថែទាំសុខភាពដែលពេញលេញជាងទីកន្លែងផ្សេងទៀត ប៉ុន្តែជាជាងការផ្តល់ព័ត៌មានដែលច្បាស់លាស់អំពីការបញ្ឈប់មានផ្ទៃពោះជូនដល់អ្នកទទួលពិនិត្យទាំងឡាយ ដើម្បីឱ្យពួកគេធ្វើការសម្រេចចិត្តដោយខ្លួនឯងនោះ គោលបំណងរបស់ទីកន្លែងទាំងនេះគឺជំរុញស្ត្រីនានាមិនឱ្យធ្វើការយកកូនចេញ។ ជាញឹកញាប់ ទីកន្លែង CPCs នៅទូទាំងសហរដ្ឋអាមេរិកផ្តល់ព័ត៌មានផ្នែកពេទ្យដែលមិនពិតជូនដល់អតិថិជនទាំងឡាយ។

ការកំណត់ថាគ្លីនិកមួយគឺជាគ្លីនិកផ្នែកពេទ្យពិតប្រាកដ ឬក៏ជាទីកន្លែង CPC នោះ អាចជាការពិបាក ដូច្នេះ សូមពិនិត្យមើលតារាងព័ត៌មានការពិតរបស់យើងខ្ញុំអំពី CPC នៅទីនេះ។

អង្គការ Reproaction មានបញ្ជីរាយគ្លីនិកក្លែងក្លាយប្រឆាំងនឹងការយកកូនចេញនៅក្នុងសហរដ្ឋអាមេរិក ដែលជំទាស់នឹងការយកកូនចេញ បង្អាប់ដល់ការថែទាំផ្នែកការយកកូនចេញ ឬក៏គាំទ្រដល់វិធីផ្សេងទៀតដែលមិនមែនជាការយកកូនចេញ។ សូមពិនិត្យមើលបញ្ជីរាយឈ្មោះគ្លីនិក នៅទីនេះ។

នៅក្នុងរដ្ឋ California លោកអគ្គមេធាវី Rob Bonta បានចេញសេចក្តីប្រកាសដល់អតិថិជនដែលឱ្យប្រជាជនរដ្ឋ California មានការប្រុងប្រយ័ត្ននៅពេលកំពុងស្វែងរកសេវាកម្មផ្នែកសុខភាពបន្តពូជចំពោះសេវាកម្មផ្សេងៗផ្តល់ជូនដោយមណ្ឌលដោះស្រាយវិបត្តិនៃការមានផ្ទៃពោះទាំងឡាយដែលមានកំណត់ និងក្នុងសភាពដែលទំនងជានឹងនាំឱ្យយល់ខុស។ ប្រជាជនរដ្ឋ California ដែលជឿជាក់ថាពួកគេបានរងគ្រោះ ឬជាគោលដៅនៃដំណើរការដែលជាការឆបោក ឬជាការនាំឱ្យយល់ខុស ឬក៏ជាការខុសច្បាប់នោះ គួរតែដាក់ពាក្យបណ្តឹងអំពីការមិនពេញចិត្តឱ្យបានភ្លាមៗ នៅលើគេហទំព័រ oag.ca.gov/crisis-pregnancy-center-complaint។

ប្រសិនបើអ្នកកំពុងពិចារណាអំពីការយកកូនចេញ និងចង់ទទួលបាននូវការប្រឹក្សា ឬការថែទាំផ្នែកពេទ្យដែលមានគុណភាពខ្ពស់ ហើយដែលត្រឹមត្រូវតាមលក្ខណៈពេទ្យនោះ សូមឱ្យប្រាកដថាអ្នកធ្វើការណាត់ជួបជាមួយនឹងទីភ្នាក់ងារថែទាំសុខភាពដែលមានកេរ្តិ៍ឈ្មោះល្អ និងមានអាជ្ញាប័ណ្ណត្រឹមត្រូវ ដូចជាទីភ្នាក់ងារទាំងឡាយដែលបានរៀបរាប់នៅក្នុងបញ្ជីរាយធនធានផ្សេងៗនេះជាដើម។

## តើខ្ញុំត្រូវបង់ប្រាក់សម្រាប់ការយកកូនចេញដោយរបៀបណាខ្លះ?

**ការបង់ប្រាក់សម្រាប់ការយកកូនចេញ – ថ្លៃចំណាយទាក់ទងទៅនឹងការថែទាំផ្នែកពេទ្យ**
នៅក្នុងរដ្ឋ California ការយកកូនចេញគឺមានចេញថ្លៃចំណាយជូនដោយធានារ៉ាប់រងសុខភាព រួមទាំងតាមរយៈកម្មវិធីធានារ៉ាប់រង Medi-Cal សម្រាប់អ្នកដែលមានប្រាក់ចំណូលទាប ផងដែរ។ នរណាម្នាក់ក៏អាចដាក់ពាក្យស្នើសុំចូលជាសមាជិកកម្មវិធីធានារ៉ាប់រង Medi-Cal បានផងដែរនៅពេលដែលពួកគេមានផ្ទៃពោះ ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ (សូមមើលផ្នែក *កម្មវិធីធានារ៉ាប់រង Medi-Cal* នៅបន្ទាប់នេះ សម្រាប់ព័ត៌មានបន្ថែម)។

### កម្មវិធីធានារ៉ាប់រង Medi-Cal

Medi-Cal គឺជាកម្មវិធីធានារ៉ាប់រងសុខភាពរបស់រដ្ឋ California សម្រាប់អ្នកដែលមានប្រាក់ចំណូលទាប។ អ្នកអាចដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ពីកម្មវិធីធានារ៉ាប់រង Medi-Cal បានដោយមិនគិតអំពីអាយុ ភេទ ជាតិសាសន៍ សាសនា ពណ៌សម្បុរ ប្រទេសកំណើត ចំណូលចិត្តផ្លូវភេទ (ថាស្រឡាញ់ភេទអ្វី) ស្ថានភាពគ្រួសារ ពិការភាព ស្ថានភាពជាអតីតទាហាន ឬស្ថានភាពអន្តោប្រវេសន៍ឡើយ។

**ទាំងកម្មវិធីធានារ៉ាប់រង Medi-Cal ដែលមានល័ក្ខខ័ណ្ឌ (Restricted Medi-Cal) (សម្រាប់តែសេវាកម្មក្នុងករណីបន្ទាន់ និងផ្នែកផ្ទៃពោះប៉ុណ្ណោះ) និងកម្មវិធីធានារ៉ាប់រង Medi-Cal ដែលទាក់ទងទៅនឹងការមានផ្ទៃពោះ (Pregnancy-Related Medi-Cal) គឺចេញថ្លៃចំណាយចំពោះតម្រូវការផ្នែកសុខភាពក្នុងអំឡុងពេលមានផ្ទៃពោះ ព្រមទាំងសម្រាប់ពេលសម្រាលកូន ឬករណីកូនស្លាប់មុនកើត ឬក៏ការយកកូនចេញ ហើយនិងការថែទាំផ្នែកពេទ្យសម្រាប់រយៈពេល 12 ខែ បន្ទាប់ពីមានផ្ទៃពោះរួចផងដែរ ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។** សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖
https://www.dhcs.ca.gov/Get-Medi-Cal/Pages/pregnancy.aspx

- **ប្រសិនបើអ្នករស់នៅក្នុងរដ្ឋ California ហើយមានសិទ្ធិដោយផ្អែកទៅលើប្រាក់ចំណូលនោះ អ្នកអាចទទួលបានការចេញថ្លៃចំណាយជូនជាបណ្ដោះអាសន្នភ្លាមៗដោយកម្មវិធីធានារ៉ាប់រង Medi-Cal សម្រាប់ការថែទាំផ្នែកការយកកូនចេញតាមរយៈ កម្មវិធីការមានសិទ្ធិទទួលបានជំនួយតាមការសន្មតសម្រាប់ស្ត្រីមានផ្ទៃពោះ (Presumptive Eligibility for Pregnant Women Program/PE4PW)។ ដើម្បីទទួលបានជំនួយ សូមចូលទៅកាន់គេហទំព័រ៖** http://publichealth.lacounty.gov/mch/choi/CHOIContractorList EngSp.pdf។
- **ស្វែងយល់បន្ថែមអំពី PE4PW៖** https://www.dhcs.ca.gov/services/medi-cal/eligibility/Pages/PE_Info_women.aspx
- **Medi-Cal Non-Medical Transportation Benefit (NMT)៖** NMT គឺជាការដឹកជញ្ជូនទៅនិងមកពីទីតាំងផ្ដល់សេវាកម្មមួយដែលមានចេញថ្លៃចំណាយជូនដោយកម្មវិធីធានារ៉ាប់រង Medi-Cal។ មនុស្សគ្រប់រូបដែលបានចុះឈ្មោះនៅក្នុងកម្មវិធីធានារ៉ាប់រង Medi-Cal អាចប្រើប្រាស់សេវាកម្មនេះបាន រួមទាំងអ្នកដែលមានផ្ទៃពោះ រហូតដល់ចុងបញ្ចប់នៃរយៈពេល 12 ខែ បន្ទាប់ពីមានផ្ទៃពោះរួចផងដែរ

ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖ https://www.dhcs.ca.gov/services/medi-cal/Pages/Transportation_General_FAQ.aspx

**ទទួលបានជំនួយសម្រាប់ការដាក់ពាក្យស្នើសុំការចេញថ្លៃចំណាយដែលមិនគិតថ្លៃ ឬគិតថ្លៃទាបតាមរយៈកម្មវិធី Community Health Outreach Initiative (CHOI) នៅលើគេហទំព័រ៖** http://publichealth.lacounty.gov/mch/choi/choi.htm។

**កំណត់សម្គាល់៖ ការដាក់ពាក្យស្នើសុំចូលជាសមាជិកកម្មវិធីធានារ៉ាប់រង Medi-Cal ក្នុងនាមជាជនអន្តោប្រវេសន៍ មិនថាស្របច្បាប់ ឬមិនស្របច្បាប់ក៏ដោយនោះ នឹងមិនប៉ះពាល់ទៅសមត្ថភាពរបស់អ្នកក្នុងការដាក់ពាក្យស្នើសុំផ្លាស់ប្តូរស្ថានភាពអន្តោប្រវេសន៍ផ្សេងៗ (ដូចជាការស្នើសុំចូលសញ្ជាតិ) នាពេលអនាគតឡើយ។**

**ការបង់ប្រាក់សម្រាប់ការយកកូនចេញ ដោយប្រើប្រាស់ធានារ៉ាប់រងឯកជន**
ច្បាប់នៃរដ្ឋ California តម្រូវចាំបាច់ឱ្យផែនការធានារ៉ាប់រងសុខភាពឯកជនភាគច្រើនចេញថ្លៃចំណាយចំពោះសេវាកម្មផ្នែកការយកកូនចេញ ដោយមិនមានការបង់ប្រាក់ដែលនៅសេសសល់ក្រោយក្រុមហ៊ុនធានារ៉ាប់រងបានបង់ខ្លះរួច (co-payment) ឬការបង់ប្រាក់ឱ្យបានគ្រប់កម្រិតផែនការធានារ៉ាប់រង (deductible) ឬក៏ការចែករំលែកការចេញថ្លៃចំណាយក្នុងប្រភេទណាមួយឡើយ។ ប្រសិនបើអ្នកមានធានារ៉ាប់រងឯកជន សូមពិនិត្យផែនការថែទាំសុខភាពរបស់អ្នក ពីព្រោះប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងមិនមានទីតាំងធំរបស់ពួកគេនៅក្នុងរដ្ឋ California ទេនោះ ការចេញថ្លៃចំណាយសម្រាប់ការយកកូនចេញអាចនឹងមានភាពខុសគ្នា អាស្រ័យទៅលើច្បាប់ផ្សេងៗរបស់រដ្ឋ (ស្តេត) នោះ។

**ជំនួយផ្សេងទៀតសម្រាប់ការបង់ប្រាក់ចំពោះការយកកូនចេញ**
ជាញឹកញាប់ ការទទួលធ្វើការយកកូនចេញមាន**ការចំណាយដែលលើសពីការចេញថ្លៃថែទាំផ្នែកពេទ្យទៀតផង។** មូលនិធិផ្នែកការយកកូនចេញ (abortion funds) គឺជាអង្គការបែបឯកជនដែលអាចជួយចេញថ្លៃចំណាយនៃការយកកូនចេញបាន ក៏ដូចជាការចេញថ្លៃចំណាយពីហៅប៉ៅទៅលើដំណើរការចាត់ចែងចំណុចផ្សេងៗ ឬជំនួយដែលអាចអនុវត្តទៅបានផ្សេងៗ រួមមានការធ្វើដំណើរ ការស្នាក់នៅ ថ្លៃម្ហូបអាហារ ការមើលថែទាំកុមារ សេវាកម្មបកប្រែឯកសារ អ្នកផ្តល់ជំនួយ (doulas/ឌូឡា) ផ្នែកការយកកូនចេញ ហើយនិងការចំណាយសម្រាប់ការយកកូនចេញ ផងដែរ (សម្រាប់ទាំងប្រជាជនរដ្ឋ California និងអ្នកដែលមកពីរដ្ឋផ្សេង)។ មូលនិធិផ្នែកការយកកូនចេញនានាមិនពិនិត្យរកស្ថានភាពអន្តោប្រវេសន៍ ឬភ័ស្តុតាងនៃការមានសញ្ជាតិឡើយ។

### សេវាកម្មផ្សេងៗទាក់ទងទៅនឹងជំនួយដែលអាចអនុវត្តទៅបាន និងការស្វែងរកទិសដៅចំពោះការយកកូនចេញនៃទីក្រុង Los Angeles/រដ្ឋ California៖

**ACCESS Reproductive Justice**
គេហទំព័រ៖ https://accessrj.org/
(បម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បត្តិ៍ ចាប់ពីម៉ោង 10 ព្រឹក ដល់ម៉ោង 4 ល្ងាច)
បណ្តាញទូរស័ព្ទថែទាំសុខភាពជាភាសាអង់គ្លេស៖ 800-376-4636

បណ្តាញទូរស័ព្ទថែទាំសុខភាពជាភាសាអេស្ប៉ាញ៖ 888-442-2237
បណ្តាញទូរស័ព្ទថែទាំសុខភាពសម្រាប់ផ្ញើសារជាអក្សរ៖ 510-925-0335
ផ្តល់ព័ត៌មានដោយមិនគិតថ្លៃ និងមានរក្សាការសម្ងាត់ ព្រមទាំងការបញ្ជូនឈ្មោះ ការគាំទ្រមតិ ហើយនិងការប្រឹក្សាពីអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នាអំពីបញ្ហាសុខភាពបន្តពូជ និងបញ្ហាសុខភាពផ្លូវភេទជាច្រើនប្រភេទ ដោយមានឯកទេសជាពិសេសលើជម្រើសនៃការមានផ្ទៃពោះ និងសេវាកម្មផ្នែកការយកកូនចេញផងដែរ។

**Maternal and Child Health Access (MCHA)**
https://www.mchaccess.org/

លេខទូរស័ព្ទរបស់ MCHA៖ 213.749.4261 (ច័ន្ទ ដល់ សុក្រ 9 ព្រឹក ដល់ 5 ល្ងាច)។ ពួកគេនិយាយភាសាអេស្ប៉ាញ ផងដែរ។

ផ្តល់ព័ត៌មានថាគួរតែធ្វើបែបណា និងផ្តល់ជំនួយដល់បុគ្គលទាំងឡាយទាក់ទងទៅនឹងការចេញថ្លៃចំណាយផ្នែកសុខភាព ព្រមទាំងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់ពួកគេ ដើម្បីធានាថាការថែទាំគឺទាន់ពេលវេលា និងត្រឹមត្រូវ។ ពួកគេផ្តល់ជំនួយក្នុងការដោះស្រាយបញ្ហាទាក់ទងទៅនឹងការសិទ្ធិទទួលបានធានារ៉ាប់រង ជម្រើសនៃការចេញថ្លៃចំណាយជូន ហើយនិងការចុះឈ្មោះចូលកម្មវិធីធានារ៉ាប់រង Medi-Cal ឬ Covered California ឬ Medi-Cal Access Program ហើយនិងធានារ៉ាប់រងសុខភាពឯកជននានាផងដែរ។ ពួកគេអាចនឹងផ្តល់ជំនួយផ្នែកប្រាក់កាស និងជំនួយផ្សេងទៀតផ្នែកការយកកូនចេញចំពោះការចាយវាយ ដូចជាការមើលថែទាំកុមារ ការធ្វើដំណើរ និងការស្នាក់នៅ ជាដើម។

**សេវាកម្មផ្នែកការស្វែងរកទិសដៅចំពោះការយកកូនចេញរបស់អ្នកធ្វើការបម្រើផ្លូវភេទ (SWANs), គម្រោងជំនួយស្តីពីអ្នកធ្វើការបម្រើផ្លូវភេទ LA (SWOP LA)**
https://swoplosangeles.org/sex-workers-abortion-navigation-services/
លេខទូរស័ព្ទ: 657-549-4556; អ៊ីម៉ែល៖ swoplaswans@proton.me
សេវាកម្មផ្នែកការស្វែងរកទិសដៅចំពោះការយកកូនចេញរបស់អ្នកធ្វើការបម្រើផ្លូវភេទ (SWANs) គឺជាគម្រោងរបស់ SWOP LA ដែលផ្តល់ការគាំទ្រដល់ការយកកូនចេញដោយមានជំនួយផ្នែកហិរញ្ញវត្ថុ និងជំនួយពីអ្នកធ្លាប់មានបទពិសោធន៍ឆ្លងកាត់សម្រាប់អ្នកដែលមានបំណងយកកូនចេញ។

## ធនធានថ្នាក់ជាតិផ្សេងៗ៖

**National Abortion Hotline (បណ្តាញទូរស័ព្ទបន្ទាន់ថ្នាក់ជាតិទាក់ទងទៅនឹងការយកកូនចេញ)**
បណ្តាញទូរស័ព្ទបន្ទាន់ដែលមានជាច្រើនភាសា៖ 800.772.9100 (ចន្ទ-សុក្រ 5 ព្រឹក - 4 ល្ងាច PT & សៅរ៍-អាទិត្យ 5 ព្រឹក-1 ថ្ងៃ PT)
។ បណ្តាញសន្ទនាបន្ទាន់ នៅលើ
គេហទំព័រ៖ prochoice.org/patients/naf-hotline
ផ្តល់ព័ត៌មានអំពីអ្នកផ្តល់សេវាកម្មផ្នែកការយកកូនចេញទាំងឡាយ និងជំនួយផ្នែកប្រាក់កាសដែលមានកំណត់ នៅក្នុងសហរដ្ឋអាមេរិក និងប្រទេសកាណាដា។

**National Network of Abortion Funds (បណ្តាញថ្នាក់ជាតិនៃមូលនិធិផ្នែកការយកកូនចេញ)**

គេហទំព័រ៖ https://abortionfunds.org/
National Network of Abortion Funds
ភ្ជាប់ទំនាក់ទំនងអ្នកប្រើប្រាស់ទាំងឡាយទៅនឹងអង្គការនានាដែលអាចជួយបំពេញតាមតម្រូវការផ្នែកការបង់ប្រាក់ និងតម្រូវការផ្នែកដំណើរការចាត់ចែងចំណុចផ្សេងៗ នៅពេលដែលស្ត្រីរៀបចំសម្រាប់ធ្វើការយកកូនចេញ។

**Women's Health Specialists**
គេហទំព័រ៖ https://www.womenshealthspecialists.org/
លេខទូរស័ព្ទ៖ 800-714-8151 (បើកបម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8:30 ព្រឹក ដល់ម៉ោង 5 ល្ងាច)
ធនធាននេះផ្តល់ការគាំទ្រ ការអប់រំ និងសេវាកម្មផ្នែកសុខភាពបន្តពូជ។

**Women's Reproductive Rights Assistance Fund (WRRAP)**
គេហទំព័រ៖ https://wrrap.org/
អង្គការ WRRAP សហការដោយផ្ទាល់ជាមួយនឹងគ្រូពេទ្យ គ្លីនិក និងមន្ទីរពេទ្យច្រើនជាង 700 នាក់/កន្លែង ហើយមិនមែនជាមួយនឹងអ្នកជំងឺទេ ដើម្បីធ្វើការផ្តល់ប្រាក់ជំនួយក្នុងការយកកូនចេញ ទាំងវិធីប្រើប្រាស់ថ្នាំពេទ្យ និងវិធីវះកាត់ សម្រាប់ស្ត្រីទាំងឡាយនៅទូទាំងសហរដ្ឋអាមេរិក រួមទាំងនៅក្នុងរដ្ឋ California និងខោនធី LA ផងដែរ។ សូមទាក់ទងទៅកាន់ពួកគេតាមរយៈគ្លីនិក ឬគ្រូពេទ្យរបស់អ្នក។

## តើខ្ញុំអាចទទួលបានការថែទាំផ្នែកការទប់ស្កាត់ការមានផ្ទៃពោះ ឬការពន្យារកំណើតផ្សេងទៀតនៅទីណាខ្លះ?

**Community Clinic Association of LA County (CCALAC)**
អង្គការ CCALAC តំណាងឱ្យគ្លីនិកនៅក្នុងសហគមន៍ និងមណ្ឌលថែទាំសុខភាពទាំងឡាយដែលមិនរកប្រាក់ចំណេញ ហើយដែលបើកដំណើរការទីតាំងផ្តល់សេវាកម្មផ្នែកថែទាំចម្បងនានានៅទូទាំងខោនធី។ គ្លីនិកទាំងឡាយនៅក្នុងសហគមន៍ផ្តល់ជូនការថែទាំសុខភាពចម្បង រួមមានសេវាកម្មផ្នែកសុខភាពផ្លូវកាយ ផ្នែកសុខភាពមាត់ធ្មេញ ផ្នែកសុខភាពផ្លូវចិត្ត និងផ្នែកការពន្យារកំណើត ជូនដល់ប្រជាជនដែលមិនមានធានារ៉ាប់រង អ្នកដែលមិនមានធានារ៉ាប់រងគ្រប់គ្រាន់ និងអ្នកដែលមិនមានធនធានគ្រប់គ្រាន់។ ដើម្បីស្វែងរកគ្លីនិកមួយដែលនៅជិតអ្នក សូមចូលទៅកាន់គេហទំព័រ៖ https://ccalac.org/find-a-clinic/។

**Family PACT Providers**
Family PACT ផ្តល់សេវាកម្មផ្នែកការរៀបចំផែនការគ្រួសារយ៉ាងពេញលេញជូនដល់បុរស និងស្ត្រីដែលមានប្រាក់ចំណូលទាប ហើយដែលមានសិទ្ធិអាចទទួលបាន នៅក្នុងរដ្ឋ California។ ដើម្បីស្វែងរកអ្នកផ្តល់សេវាកម្ម Family PACT មួយដែលនៅជិតអ្នក សូមចូលទៅកាន់គេហទំព័រ៖ https://familypact.org/provider-search/។

**Federally Qualified Health Centers (FQHCs)**
FQHCs គឺជាអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពនៅតាមសហគមន៍ ដែលមានផ្តល់ជូនសេវាកម្មផ្នែកថែទាំចម្បងផ្សេងៗ នៅតាមតំបន់ដែលមិនបានទទួលការថែទាំគ្រប់គ្រាន់។ FQHCs នឹងផ្តល់ការថែទាំ

ប្រសិនបើអ្នកមានធានារ៉ាប់រងសុខភាព ឬបើទោះបីជាអ្នកមិនមានធានារ៉ាប់រងក៏ដោយ។ ដើម្បីស្វែងរកគ្លីនិកមួយដែលនៅជិតអ្នក សូមចូលទៅកាន់គេហទំព័រ៖ https://findahealthcenter.hrsa.gov/។

**Los Angeles County Department of Health Services, Women's Health Services (កម្មវិធីសេវាកម្មផ្នែកសុខភាពស្ត្រី របស់នាយកដ្ឋានសេវាកម្មសុខភាពនៃខោនធី Los Angeles)**
កម្មវិធីនេះផ្តល់ព័ត៌មានផ្នែកសុខភាព ការប្រឹក្សា និងសេវាកម្មផ្សេងៗផ្នែករៀបចំផែនការគ្រួសារជូនដល់មនុស្សពេញវ័យ និងក្មេងជំទង់ដែលមានប្រាក់ចំណូលទាប ដើម្បីកាត់បន្ថយឱកាសនៃការមានផ្ទៃពោះដែលមិនបានគ្រោងទុក ហើយនិងដើម្បីថែរក្សាសុខភាពបន្តពូជ ផងដែរ។ ដើម្បីស្វែងរកការថែទាំសុខភាពដែលនៅជិតអ្នក សូមចូលទៅកាន់គេហទំព័រ៖ https://dhs.lacounty.gov/womens- health/our-services/womens-health/។

**Title X Family Planning Clinic Locator**
Title X គឺជាការផ្តល់ទឹកប្រាក់ពីរដ្ឋាភិបាលដែលផ្តល់ជូនវិធីសាស្ត្រផ្នែករៀបចំផែនការគ្រួសារ ហើយនិងសេវាកម្មសុខភាពបង្ការទុកជាមុនដែលពាក់ព័ន្ធជាច្រើនប្រភេទ។ អ្នកអាចស្វែងរកគ្លីនិកផ្នែកការរៀបចំផែនការគ្រួសារបែបពេញលេញដែលផ្តល់ជម្រើសជាច្រើនប្រភេទសម្រាប់ការពន្យារកំណើត សេវាកម្មផ្នែកការឆ្លងមេរោគតាមផ្លូវភេទ (STI) ការប្រឹក្សាអំពីការធ្វើតេស្តថាមានផ្ទៃពោះឬទេ និងអំពីជម្រើសផ្នែកផ្ទៃពោះផ្សេងៗ ហើយនិងការពិនិត្យរកជំងឺមហារីកជូនដល់យុវជន និងអ្នកដែលមានប្រាក់ចំណូលទាប ផងដែរ។ ដើម្បីស្វែងរកគ្លីនិកមួយដែលនៅជិតអ្នក សូមចូលទៅកាន់គេហទំព័រ៖ https://opa-fpclinicdb.hhs.gov/។

## អ្នកផ្តល់ជំនួយ (DOULA) សម្រាប់ផ្នែកការយកកូនចេញ

ប្រសិនបើអ្នកនឹងធ្វើការយកកូនចេញនៅពេលខាងមុខ ឬកំពុងធ្វើការយកកូនចេញនាពេលនេះ ឬក៏ទើបតែយកកូនចេញរួច ហើយចង់ទទួលបានជំនួយបន្ថែមក្នុងអំឡុងពេលដំណើរការនោះ សូមពិចារណាលើការថែទាំដែលអាចទទួលបានពីអ្នកផ្តល់ជំនួយ (doula/ឌូឡា) ផ្នែកការយកកូនចេញនេះ។ ឌូឡាផ្នែកការយកកូនចេញ និងអ្នកដែលទទួលបានការបង្ហាត់ជាពិសេសផ្សេងទៀត មានសមត្ថភាពក្នុងការផ្តល់ការគាំទ្រផ្នែកផ្លូវចិត្ត និងផ្លូវកាយ មុនពេល ក្នុងអំឡុងពេល និងបន្ទាប់ពីការយកកូនចេញនៅបន្ទប់ពិនិត្យរបស់គ្រូពេទ្យ ឬក៏ការយកកូនចេញនៅផ្ទះរួចហើយនោះ។ របៀបមួយចំនួនដែលឌូឡាផ្នែកការយកកូនចេញអាចនឹងជួយអ្នកបានគឺតាមរយៈការផ្តល់ការអប់រំដល់អ្នកអំពីការយកកូនចេញដែលអ្នកនឹងមាន ការអមដំណើរជាមួយអ្នកទៅតាមណាត់ជួប (មួយ ឬច្រើន) របស់អ្នក ការចាប់កាន់ដៃលើកទឹកចិត្តដល់អ្នកខណៈពេលដែលអ្នកនៅក្នុងគ្លីនិក ហើយនិងការបន្លប់ឬនិយាយពីអារម្មណ៍ដែលមានក្នុងអំឡុងពេល ឬបន្ទាប់ពីពេលដំណើរការនេះ។ អ្នកអាចធ្វើកិច្ចការនានាជាមួយនឹងឌូឡាផ្នែកការយកកូនចេញដោយផ្ទាល់ ឬក៏តាមរយៈការនិយាយទូរស័ព្ទ ឬការផ្ញើសារជាអក្សរ។ ចំណុចសំខាន់បំផុតនោះ បុគ្គលដែលបានទទួលការបង្ហាត់ក្នុងកម្រិតខ្ពស់ ហើយមានសេចក្តីមេត្តានេះគឺនៅទីនេះ ដើម្បីគាំទ្រអ្នក និងគោរពដល់សេរីភាពបុគ្គលផ្នែកការបន្តពូជរបស់អ្នក តាមវិធីពិសេសមួយដែលស្របទៅតាមតម្រូវការផ្ទាល់ខ្លួនទាំងឡាយរបស់អ្នក។

### Birthworkers of Color
គេហទំព័រ៖ https://www.birthworkersofcolor.com/
ផ្តល់សេវាវិសាលគមពេញលេញអំពីការមានផ្ទៃពោះ និងការគាំទ្រសម្រាប់សហគមន៍ត្រូវការជំនួយ។ ជួយបុគ្គល គ្រួសារ និងសហគមន៍ទទួលបានជំនួយ (ឧ. ផ្នែកអប់រំ ផ្នែកផ្លូវចិត្ត និងរាងកាយ) ពេញមួយដំណើរការមានផ្ទៃពោះ និងក្រោយសម្រាលរបស់ពួកគេ។

### LA Abortion Support Collective
គេហទំព័រ៖ https://www.laabortionsupport.org/
ផ្តល់ព័ត៌មានអំពីជម្រើសដែលមិនគិតថ្លៃសម្រាប់ជំនួយផ្ទាល់មុខ និងជំនួយតាមអនឡាញនៅក្នុងខោនធី LA។

### Medi-Cal Doula Directory
គេហទំព័រ៖ https://www.dhcs.ca.gov/provgovpart/Pages/Doula-Services-Members.aspx
ផ្តល់ព័ត៌មានអំពីឌូឡានានានៅទូទាំងរដ្ឋ California ដោយរួមមានជំនាញឯកទេសភាសាដែលអាចនិយាយបាន និងព័ត៌មានទំនាក់ទំនងរបស់ពួកគេ ផងដែរ។

## ជំនួយផ្នែកសុខភាពផ្លូវចិត្ត

មនុស្សជាច្រើនត្រូវការជំនួយក្នុងការសម្រេចចិត្តថាត្រូវធ្វើអ្វីខ្លះនៅពេលដែលពួកគេមានផ្ទៃពោះ ហើយមិនចង់មានផ្ទៃពោះវិញ ឬមិនច្បាស់ថាពួកគេចង់ទុកឱ្យផ្ទៃពោះនោះដល់គ្រប់ខែឬយ៉ាងណា។ បើទោះបីជាការស្រាវជ្រាវជាច្រើនទសវត្សរ៍កន្លងមកនេះបានបង្ហាញថាការយកកូនចេញមិនមានផលប៉ះពាល់អវិជ្ជមានដល់សុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្តក៏ដោយ ប៉ុន្តែការដែលមនុស្សមួយចំនួនមានអារម្មណ៍មិនសប្បាយចិត្ត ឬក្រៀមក្រំនោះគឺជាចំណុចធម្មតានៅមុនពេល និងបន្ទាប់ពីការបញ្ចប់មានផ្ទៃពោះរួច។ ធនធានទាំងនេះគឺមានលក្ខណៈជាក់លាក់សម្រាប់បុគ្គលទាំងឡាយដែលកំពុងស្វែងរកការយកកូនចេញ ឬបានយកកូនចេញរួចហើយ ឬក៏កំពុងតែផ្តល់ជំនួយដល់នរណាម្នាក់ដែលបានយកកូនចេញផងដែរ។

### All-Options Talk-line
គេហទំព័រ៖ https://www.all-options.org/find-support/talkline/
លេខទូរស័ព្ទ៖ 888-493-0092 ចន្ទ-សុក្រ 7 ព្រឹក - 1 ថ្ងៃ និងសៅរ៍-អាទិត្យ 7 ព្រឹក-3 រសៀល ម៉ោងស្តង់ដារប៉ាស៊ីហ្វិក
លេខទូរស័ព្ទ៖ 888-493-0092 បម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 10 ព្រឹក ដល់ម៉ោង 1 យប់ និងថ្ងៃសៅរ៍/ថ្ងៃអាទិត្យ ចាប់ពីម៉ោង 10 ព្រឹក ដល់ម៉ោង 6 ល្ងាច
សម្រាប់រដ្ឋប៉ែកខាងកើតសហរដ្ឋអាមេរិក (សូមគិតថយក្រោយចំនួនបីម៉ោងសម្រាប់រដ្ឋ California)
ការប្រឹក្សាអំពីជម្រើសផ្សេងៗដែលមានភាពត្រឹមត្រូវទៅតាមផ្នែកពេទ្យ និងមិនលម្អៀង។

### Connect & Breathe
គេហទំព័រ៖ https://www.connectandbreathe.org/about.html
លេខទូរស័ព្ទ៖ 1-866-647-1764 បម្រើការថ្ងៃច័ន្ទ ចាប់ពីម៉ោង 4-7 យប់ ថ្ងៃអង្គារ/ព្រហស្បត្តិ៍ ចាប់ពីម៉ោង3-6 ល្ងាច ដល់ម៉ោង 9 យប់ និងថ្ងៃសៅរ៍ ចាប់ពីម៉ោង 9-12 ថ្ងៃត្រង់ ម៉ោងស្តង់ដារប៉ាស៊ីហ្វិក
អង្គការ Connect & Breathe ផ្តល់នូវវេទិកាដែលមានសុវត្ថិភាពមួយ ដើម្បីពិភាក្សាអំពីបទពិសោធន៍ទាក់ទងទៅនឹងការយកកូនចេញតាមរយៈការផ្តល់បណ្តាញទូរស័ព្ទសន្ទនាសម្រាប់ជាការគាំទ្រ និងការលើកទឹកចិត្តទៅលើការថែទាំខ្លួនឯងដោយមិនមានភាពលម្អៀង។

### Exhale Pro-Voice

គេហទំព័រ៖ https://exhaleprovoice.org/

ផ្ញើសារជាអក្សរទៅកាន់លេខ 617-749-2948 បម្រើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 3 រសៀល ដល់ម៉ោង 9 យប់ ថ្ងៃសៅរ៍ ចាប់ពីម៉ោង 1 រសៀល ដល់ម៉ោង 9 យប់ និងថ្ងៃអាទិត្យ ចាប់ពីម៉ោង 3 រសៀល ដល់ម៉ោង 7 យប់ ម៉ោងស្តង់ដារប៉ាស៊ីហ្វិក

អង្គការ Exhale Pro-Voice

ផ្តល់ជូននូវការគាំទ្របន្ទាប់ពីការយកកូនចេញរួចដោយមិនមានការវាយតម្លៃទុកជាមុនសម្រាប់ពេលក្រោយការយកកូនចេញ និងសម្រាប់អ្នកដែលកំពុងមានបំណងចង់ជួយគាំទ្រដល់ដៃគូ ឬដល់មនុស្សវ័យក្មេង ឬក៏មិត្តភក្តិ បន្ទាប់ពីការយកកូនចេញរបស់ពួកគេរួច។ វាអាចចំណាយពេលរហូតដល់ 24 ម៉ោងដើម្បីទទួលបានការឆ្លើយតបដំបូងបន្ទាប់ពីការផ្ញើសារសម្រាប់ការគាំទ្រ។

### Faith Aloud (Non-Judgmental Faith based Support) (ជំនួយផ្នែកទៅលើសាសនាដែលមិនធ្វើការវាយតម្លៃទុកជាមុន)

គេហទំព័រ៖ https://www.faithaloud.org/

លេខទូរស័ព្ទ៖ 888-717-5010

ច័ន្ទ/ពុធ/សុក្រ 8 ព្រឹក - 3 រសៀល ម៉ោងស្តង់ដារប៉ាស៊ីហ្វិក និងសៅរ៍/អាទិត្យ 9 ព្រឹក - 12 យប់ ម៉ោងស្តង់ដារប៉ាស៊ីហ្វិក

សូមទូរស័ព្ទទៅដើម្បីទទួលបានការគាំទ្រផ្នែកសាសនា និងអារម្មណ៍ផ្លូវចិត្តដោយក្តីមេត្តាធម៌ចំពោះការយកកូនចេញ និងជម្រើសនៃការមានផ្ទៃពោះ។ អ្នកបួសសាសនា និងអ្នកប្រឹក្សាផ្នែកសាសនានឹងស្តាប់នូវអ្វីដែលអ្នកចង់និយាយ ហើយផ្តល់នូវជំនួយគាំទ្រដោយមិនធ្វើការវាយតម្លៃទុកជាមុនឡើយ។

### Miscarriage + Abortion Hotline (បណ្តាញទូរស័ព្ទបន្ទាន់ទាក់ទងទៅនឹងករណីកូនស្លាប់មុនកើត និងការយកកូនចេញ)

គេហទំព័រ៖ https://www.mahotline.org/

លេខទូរស័ព្ទ៖ 833-246-2632 បម្រើការចាប់ពីម៉ោង ពីម៉ោង 9 ព្រឹកដល់ម៉ោង 9 យប់ ម៉ោងស្តង់ដារប៉ាស៊ីហ្វិក

ស្វែងរកជំនួយការសម្ងាត់ និងស្វ័យគ្រប់គ្រងការរលូតកូន ឬការយកកូនចេញរបស់អ្នកដោយរក្សាការសម្ងាត់។ សូមទូរស័ព្ទ ឬផ្ញើសារជាអក្សរទៅកាន់បុគ្គលិកនៅគ្លីនិកដែលមានបទពិសោធន៍ជាច្រើនឆ្នាំលើផ្នែកថែទាំសម្រាប់ករណីកូនស្លាប់មុនកើត និងការយកកូនចេញ។

### Reprocare Healthline

គេហទំព័រ៖ https://reprocare.com/

លេខទូរស័ព្ទ៖ 833-226-7821 បម្រើការចាប់ពីម៉ោង 9 ព្រឹក ដល់ម៉ោង 9 យប់ សម្រាប់រដ្ឋប៉ែកខាងលិចសហរដ្ឋអាមេរិក (ដូចជារដ្ឋ California) ហើយអាចទូរស័ព្ទទៅបាន 7 ថ្ងៃក្នុងមួយសប្តាហ៍

ផ្តល់ជំនួយផ្នែកសតិអារម្មណ៍ ព័ត៌មានផ្នែកពេទ្យ និងការបញ្ជូនឈ្មោះពីអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នាក្នុងលក្ខណៈមិនបញ្ចេញឈ្មោះ ជូនដល់អ្នកដែលកំពុងធ្វើការយកកូនចេញនៅផ្ទះដោយប្រើប្រាស់ថ្នាំគ្រាប់។

## សិទ្ធិផ្នែកការយកកូនចេញ និងផ្នែកពន្យារកំណើត នៅក្នុងរដ្ឋ California

**ACLU Southern California**

គេហទំព័រ៖ https://www.aclusocal.org/en/know-your-rights/abortion-care-california

អង្គការ ACLU Southern California ផ្តល់ព័ត៌មានអំពីសិទ្ធិផ្នែកការយកកូនចេញនៅក្នុងរដ្ឋ California។ គេហទំព័រនេះគឺធ្វើឱ្យមានព័ត៌មានទាន់ហេតុការណ៍ជាប្រចាំ នៅពេលដែលច្បាប់នានាមានការផ្លាស់ប្តូរ។

**Advocates for Youth - Free the Pill**

គេហទំព័រ៖ https://www.advocatesforyouth.org/campaigns/free-the-pill/

អង្គការ Advocates for Youth សហការជាមួយនឹងមនុស្សវ័យក្មេងរាប់ពាន់នាក់នៅក្នុងសហរដ្ឋអាមេរិកនេះ និងនៅជុំវិញពិភពលោក ខណៈដែលពួកគេតស៊ូដើម្បីឱ្យមានសុខភាពផ្លូវភេទ សិទ្ធិ និងយុត្តិធម៌ត្រឹមត្រូវ។

**California Consumer Alert: Right to Access Free or Low-Cost Birth Control (សេចក្តីប្រកាសដល់អតិថិជននៅក្នុងរដ្ឋ California៖ សិទ្ធិក្នុងការទទួលបានមធ្យោបាយពន្យារកំណើតដែលមិនគិតថ្លៃ ឬគិតថ្លៃទាប)**

ច្បាប់ចម្លងនៃសេចក្តីប្រកាសដល់អតិថិជននេះគឺអាចរកបាន នៅទីនេះ។ ប្រសិនបើអ្នកគឺជាប្រជាជនរដ្ឋ California អ្នកមានជម្រើសដើម្បីទទួលបានមធ្យោបាយពន្យារកំណើតដែលមិនគិតថ្លៃ ឬគិតថ្លៃទាប ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។

**Teen Source**

គេហទំព័រ៖ https://www.teensource.org/know-your-rights

Teen Source គឺជាវេទិកាតាមអនឡាញមួយដើម្បីទទួលបានព័ត៌មាន ហើយនិងធនធានផ្សេងៗទាក់ទងទៅនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជដែលសមស្របសម្រាប់ការចែកជូនទៅក្មេងជំទង់បាន។ គេហទំព័រនេះមានផ្តល់ជូនព័ត៌មានដែលត្រឹមត្រូវ និងអាចទុកចិត្តបានអំពីជំងឺឆ្លងតាមផ្លូវភេទ (STDs) ផ្សេងៗ មធ្យោបាយពន្យារកំណើត ការមានទំនាក់ទំនងជាមួយនឹងអ្នកដទៃដែលប្រកបទៅដោយការគោរពនិងការជឿជាក់ ហើយនិងសិទ្ធិនានារបស់ក្មេងជំទង់ក្នុងការទទួលបានសេវាកម្មផ្សេងៗដែលអាចធ្វើឱ្យមានភាពខ្មាស់អៀន (ដូចជាសេវាកម្មសុខភាពផ្លូវភេទ ជាដើម) នៅក្នុងរដ្ឋ California។